## តើអ្នកយល់ព្រមចំពោះការផាកពិន័យឪពុកម្តាយ ដែលកូនរបស់គេគេជមិនចូលសាលាទេ?

ឪពុកម្តាយទាំងឡាយ ដែលកូនគេជមិនចូលសាលា នឹងត្រូវបានផាកពិន័យជាប្រាក់ចំនួន ៣០០ដុល្លា ជាលើកដំបូង និងចំនួន ៣០០០ដុល្លា ចំពោះករណីក្រោយៗ ក្រោមច្បាប់ថ្មីដែលកំពុងតែធ្វើនៅឯរដ្ឋសភា។

ពង្រាងច្បាប់ថ្មីស្តីពីវិសោធនកម្មវិស័យអប់រំ (បទដ្ឋានជាតិ) បានផ្តល់សិទ្ធដល់រដ្ឋមន្ត្រីក្រសួងអប់រំ នូវអំណាចក្នុងការកំណត់នូវបទដ្ឋានអក្ខរកម្ម និងលេខពន្ធ។

ប៉ុន្តែពង្រាងច្បាប់នេះក៏បានធ្វើការពិន័យទ្វេរដងចំពោះការគេចសាលាផងដែរ។ ប្រសិនបើឪពុកម្តាយពុំព្រមចុះឈ្មោះកូនឲ្យចូលរៀនទេ ការផាកពិន័យនឹងត្រូវកើនឡើងរហូតដល់ ៣០០០ដុល្លា ដែលជាចំនួនទ្វេដងនៃចំនួនដែលបានកំណត់ពីមុន។

តើអ្នកយល់ព្រមចំពោះការផាកពិន័យឪពុកម្តាយដែលកូនគេជសាលាមិនចូលរៀនទេ? ខាងក្រោមនេះ គឺជាទស្សនៈសម្រាំងល្អៗ ដែលយើងបានជ្រើសរើសសម្រាប់លោកអ្នកៈ

**LittleBlueCar (North Shore)**

អ្នកអាចឲ្យកូនរបស់លោកអ្នកទៅសាលា ប៉ុន្តែអ្នកមិនអាចឲ្យកូនរបស់អ្នករៀនបានឡើយ។ ដូច្នេះ សំនួរដែលត្រូវនឹងសួរគឺ តើហេតុអ្វីបានជាក្មេងមិនចូលសាលា? ចម្លើយគឺថា ការចូលសាលា គឺជាការធុនទ្រាន់មួយ។ ការសិក្សានៅសាលាភាគច្រើនក្នុងពេលបច្ចុប្បន្ន គឺជាការសិក្សាដែលមានតែទ្រឹស្តី គឺពុំមានការអនុវត្តឡើយ។ ការសិក្សារបស់ក្មេងៗ គឺមានលក្ខណៈផ្សេងៗគ្នា ដូចជាការរៀនការងារជាក់ស្តែងក្នុងការសាងសង់អគារ ការជួសជុលរថយន្តឬការអនុវត្តន៍គម្រោងនានាដែលយើងអាចមើលឃើញនូវទិន្នផលរបស់វា។ សាលាគួរតែជាកន្លែង ដែលអាចជួយឲ្យសិស្សយល់ដឹងពីអ្វីដែលគេអាចនឹងធ្វើបាន ក្រោយពីគេបានបញ្ចប់ការសិក្សា។វាមិនគួរជាកន្លែងដែលផ្តល់នូវអ្វីដែលគ្មានប្រយោជន៍ទៅដល់សិស្សឡើយ។

ប៉ុន្មានឆ្នាំមុន មានសាលាចំនួនពីរប្រភេទ គឺសាលាទ្រឹស្តី និងសាលាបច្ចេកទេស ហើយអ្នកបានទៅសាលាមួយរវាងសាលាទាំងពីរនេះ។ប្រហែលជាយើងត្រូវតែធ្វើការពិនិត្យឡើងវិញទាក់ទិននឹងបញ្ហានេះ។

**Mother (Albany)**

ខ្ញុំយល់ស្របជាមួយឃ្លាដែលថា "នៅពេលដែលទៅឆ្ងាយ" នៅ Whangarei។ វាជាចំនុចមួយដែលល្អមែនទែន បើទោះបីជាខ្ញុំជឿថា មានការសិក្សាជាច្រើន ដែលអាចត្រូវបានធ្វើឡើងនៅក្នុងសាលា ខ្ញុំក៏ជឿថាការ សិក្សាមួយចំនួនគឺត្រូវធ្វើឡើងនៅក្រៅសាលាដែរ ដូចជាការធ្វើដំណើរ និង បទពិសោធន៍ជីវិត ដែលកត្តាទាំងនេះធ្វើឲ្យសិស្សមានអារម្មណ៍ថា វាគឺជារឿងដែលមានតម្លៃបំផុតក្នុងការរៀនពេលខ្លះ ប៉ុន្តែមិនចាំបាច់រៀនគ្រប់ពេលឡើយ។

ហេតុអ្វីបានជាក្មេងៗត្រូវបានបង្ខំឲ្យរៀននៅក្នុងថ្នាក់រៀន ដែលមានលក្ខណៈធុញទ្រាន់ មិនគួរឲ្យចាប់អារម្មណ៍ ហើយមែនហើយ ពួកគេក៏អាចក្លាយទៅជាសិស្សពេញវ័យបានដោយខ្លួនឯងដោយពុំមានបញ្ហា។ ហេតុអ្វីបានជាឱពុកម្តាយ ដែលគ្មានបង្កបញ្ហាអ្វីត្រូវបានផាកពិន័យ?វាពុំមានន័យអ្វីឡើយ។

**Craig (Glen Eden)**

ច្បាប់ថ្មីនេះបានបើកឱកាសឲ្យមានការផាកពិន័យចំពោះឪពុកម្តាយ ដែលកូនរបស់ពួកគេគេជមិនចូលសាលា។ ជាតិទាំងមូលពុំបានធ្វើអ្វី ដើម្បីស្វែងយល់ឲ្យបានច្បាស់លាស់ពីបញ្ហាគេជសាលានោះឡើយ។ បញ្ហានេះគឺជាបញ្ហានយោបាយច្រើនជាង។

ហើយចំពោះករណីលើកស្ទួយនូវបទដ្ឋានអប់រំ នេះគឺជារឿងកំប្លែង។ ជាតិទាំងមូលបានធ្វើដំណើរទៅរកស្ថានភាព Nanny State Labour។ ឥឡូវនេះពួកគេបានកាន់អំណាចហើយតើអ្វីខ្លះដែលគេបានធ្វើ ហើយបញ្ហាទៅដល់គ្រូបង្រៀនទាំងអស់នូវអ្វីដែលគេគួរធ្វើ ក្នុងការងាររបស់គេ។

តើរដ្ឋាភិបាលមានភាពឆ្មើងកន្ទ្រើងប៉ុណ្ណា ក្នុងការអនុម័តច្បាប់ស្តីពីបទដ្ឋានអក្ខរកម្ម និងការអប់រំ ដោយពុំមានធ្វើការពិភាក្សាជាមួយអ្នកជំនាញដែលពាក់ព័ន្ធ។ ខ្ញុំសង្ស័យថា ពួកគេមិនចង់មាននូវការពិភាក្សាទេ ព្រោះពួកគេមិនចង់ឮនូវអ្វីដែលអាក្រក់ៗឡើយ។

ខ្ញុំអាចទាយបានថា គោលការណ៍ទាំងនេះមិនចាំបាច់ឲ្យមានឡើយ ហើយមិនបានជួយអ្វីទាល់តែសោះដល់ក្មេងៗណ្វារ៉េលហ្សេឡង់ទាក់ទងនឹងការអប់រំ។

**Mother (Albany)**

នេះគឺជាច្បាប់ដែលមិនអាចទៅរួច។មានតែមនុស្សដែលខ្វះខាតនូវជំនាញតក្កវិជ្ជា
មនុស្សដែលពុំមានកូននិងមនុស្សដែលពុំយល់ប៉ុណ្ណោះ ដែលយល់ស្របជាមួយច្បាប់នេះ។
នេះគឺជាទម្រង់មួយផ្សេងទៀតនៃ"NannyState"។
ឱពុកម្តាយតែងតែត្រូវបានដាក់នៅចន្លោះដុំថ្ម និងកន្លែងរឹងៗ។

**Colin Sansom (Howick)**

ការគេជសាលាគឺជាការមិនទទួលខុសត្រូវ ហើយគឺជាការទ្វេសប្រហែស ជាពិសេសប្រសិនណាបើឪពុកម្តាយបានជម្រុញ និងលើកទឹកចិត្តក្នុងការគេជសាលាបែបនេះ ដែលអាចមានការប៉ះពាល់ដល់អនាគតរបស់ក្មេងៗទាំងនោះ។ លើសពីនេះទៅទៀត ឪពុកម្តាយទាំងនោះ គឺកំពុងតែបង្កើតជាគម្រូអាក្រក់មួយសម្រាប់ក្មេងៗជំនាន់ក្រោយ។ មែនហើយ ឪពុកម្តាយដែលល្អ គឺជាឪពុកម្តាយ ដែលអាចធ្វើជាគម្រូដ៍ល្អសម្រាប់កូនៗរបស់ពួកគេជាដំបូង។

**robert ambrose (Te Atatu South)**

មែនហើយ កន្លែងលក់ដូរនានា និងផ្សារទំនើប អាចជួយតាមដាននូវការគេជសាលានេះ ដោយធ្វើការហាមប្រាមមិនឲ្យសិស្សសាលាពីម៉ោង ៩ ដល់ម៉ោង ២ ប្រសិនណាបើពួកគេមិនទៅជាមួយឪពុកម្តាយរបស់ពួកគេទេ។

# ការហូរចូលនូវបណ្តឹងចំពោះអាជ្ញាធ័របទដ្ឋានផ្សព្វផ្សាយ

មានមនុស្សកាន់តែច្រើនឡើងនៅក្នុងឆ្នាំនេះបានធ្វើបណ្តឹងចំពោះប្រព័ន្ធផ្សព្វផ្សាយទៅកាន់អជ្ញាធ័របទដ្ឋានផ្សព្វផ្សាយបើប្រៀបធៀបទៅនឹងឆ្នាំ ដែលកន្លងទៅ។

តាមប្រភពពីអជ្ញាធ័រនោះបានឲ្យដឹងថាខ្លួនបានទទួលនូវបណ្តឹងចំនួន១៤៨ ហើយបានធ្វើសេចក្តីសម្រេចលើបណ្តឹងចំនួន១៣៩បើប្រៀបធៀបទៅនឹងឆ្នាំមុន ដែលមានបណ្តឹងចំនួន ១៣១ និងបានដោះស្រាយរួចរាល់ ចំនួន ១២៥។

តាមរយៈរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនដែលបានធ្វើឡើងក្នុងពេលថ្មីៗនេះបានឲ្យដឹងថាការយល់ដឹងទាក់ទងនឹងដំណើរការនៃការប្តឹងផ្តល់ដែលមានសភាពល្អជាងមុនការចេញមុខជាសាធារណៈកាន់តែច្រើនឡើងៗរបស់អាជ្ញាធ័របទដ្ឋានផ្សព្វផ្សាយហើយនឹងការព្រួយបារម្ភពីសំណាក់សាធារណៈជនទូទៅទាក់ទិននឹងផលប៉ះពាល់របស់វាអាចជាហេតុផលនៃការកើនឡើងនៃបណ្តឹងទាំងនេះ។

បណ្តឹងសម្រាប់អជ្ញាធ័របទដ្ឋានផ្សព្វផ្សាយពាណិជ្ជកម្មក៍មានការកើនឡើងច្រើនដែរក្នុងឆ្នាំនេះ។

ក៏ដូចជាឆ្នាំមុនៗដែរបណ្តឹងទាំងនោះគឺមានលក្ខណៈស្មុគស្មាញហើយ
ភាគច្រើនគឺផ្តោតលើព័ត៌មានព្រឹត្តិការណ៍បច្ចុប្បន្នភាពនិងកម្មវិធីជជែក របស់វិទ្យុ។

អាជ្ញាធ័របទដ្ឋានផ្សព្វផ្សាយបានឲ្យដឹងថាខ្លួនមិនមានការភ្ញាក់ផ្អើល
ចំពោះការកើនឡើងនៃបណ្តឹងក្រោមបទដ្ឋានផ្សេងៗគ្នានោះទេរួមបញ្ចូល
ទាំងរសជាតិដែលល្អ និងសុជីវធម៌នោះ។

យោងតាមអាជ្ញាធ័របទដ្ឋានផ្សព្វផ្សាយនៅអំឡុងពេលពីរឬបីឆ្នាំមុនភាព
តានតឹងរវាងប្រព័ន្ធផ្សព្វផ្សាយក្នុងការស្វែងរករឿងនិងសិទ្ធរបស់បុគ្គល
ឯកជនបានធ្វើឲ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំង។

បច្ចេកវិទ្យាថ្មីបានធ្វើឲ្យការថតយកព្រឹត្តិការណ៍នានាមានលក្ខណៈកាន់តែងាយស្រួល
ហើយតម្រូវការជាក់ស្តែងទាក់ទិននឹងការកំសាន្តផ្អែកលើការពិត
បានជ្រៀតចូលក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប។

អាជ្ញាធ័របទដ្ឋានផ្សព្វផ្សាយបាននិយាយថាខ្លួនបានធ្វើការសម្រេចជាដុំ
កំភួនមួយនៅក្នុងកម្មវិធី Target របស់ទូរទស្សន៍នៅក្នុងឆ្នាំនេះ។

តាំងពីវាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៩កម្មវិធីបានប្រើប្រាស់"សាក
ល្បងនូវម៉ាស៊ីនថតសម្ងាត់"ដើម្បីធ្វើការស៊ើបអង្កេតនូវសេវាកម្មដែលបាន
ផ្តល់ឲ្យដោយពាណិជ្ជកររាប់រយនាក់ និងអ្នកផ្តល់សេវាកម្មនានា។

ឆ្នាំនេះអាជ្ញាធ័របទដ្ឋានផ្សព្វផ្សាយបានទទួលនិងសម្រេចនូវបណ្តឹងលើកទីមួយ
ដែលថាការផ្សព្វផ្សាយព័ត៌មានដែលបានមកពីម៉ាស៊ីនថតសម្ងាត់របស់
Targetនៅក្នុងលំនៅដ្ឋានឯកជនគឺជាការបំពានលើសិទ្ធិឯកជន
និងមានលក្ខណៈមិនយុត្តិធម៌។

សមាជិកសាធារណៈម្នាក់បានធ្វើការប្តឹងអំពីឈុតខ្លីៗរបស់Targetដែល
ធ្វើការបង្ហាញនូវរូបភាពដែលបានមកពីម៉ាស៊ីនថតសម្ងាត់នៃអ្នកមើលថៃ
ទាំចំនួន៤នាក់ដែលត្រូវបានជួលឲ្យថែទាំតារាសម្តែងចំណាស់មួយរូប
អស់រយៈពេល៤ម៉ោង។

អាជ្ញាធរបទដ្ឋានផ្សព្វផ្សាយបានរកឃើញថារូបភាពដែលបានថតដោយម៉ាស៊ីនថតសម្ងាត់គឺមានន័យស្រដៀងគ្នាទៅនឹងការជ្រៀតជ្រែកដោយ ចេតនា។

វាត្រូវបានគេនិយាយថាការថតយករូបភាពមនុស្សនៅក្នុងផ្ទះដោយកំបាំងដែលជាកន្លែងដែលគេគិតថាមានសុវត្ថិភាពឯកជនគឺជាការរំលោភលើសិទ្ធិឯកជនរបស់អ្នកដ៏ទៃរបស់កម្មវិធីនេះ។

## នាយករដ្ឋមន្ត្រីកោះប្រជុំគណៈរដ្ឋមន្ត្រីលើកដំបូង

គណៈរដ្ឋមន្ត្រីថ្មីបានជួបប្រជុំនៅថ្ងៃនេះ បីម៉ោងក្រោយពីបានធ្វើសច្ចាប្រណិធាន។ លោក នាយករដ្ឋមន្ត្រី Jonh Key បានផ្តល់ឲ្យសមាជិកគណៈរដ្ឋមន្ត្រីរបស់គាត់ដើម្បី ធ្វើការត្រួតពិនិត្យនូវភាពពិតភ្លាមៗ។

មានប្រសាសន៍ទៅកាន់អ្នកយកព័ត៌មានក្នុងខណៈពេលដែលលោកអង្គុយនៅកៅអីនៅជាន់ខាងលើ Beehive លោកបានឲ្យដឹងថា"យើងធ្វើការចាប់ផ្តើមឲ្យបានឆាប់ហើយ យើងមិនយកថ្ងៃនេះគ្រាន់តែជាថ្ងៃសម្រាប់ធ្វើការថតរូបជុំគ្នានោះទេ"។

"យើងនឹងធ្វើការចាប់ផ្តើមធ្វើកិច្ចពិភាក្សាសំខាន់ៗឲ្យបានឆាប់រហ័យ"។

សមាជិកទាំង២០រូបរបស់គណៈរដ្ឋមន្ត្រី គឺសុទ្ធតែជាសមាជិកគណបក្សជាតិ។ ក្រៅពី នេះ នៅមានសមាជិកចំនួន៣រូបផ្សេងទៀតដែលមានតំណែងនៅក្រៅគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីចំនួនប្រាំរូបទៀតមកពីគណបក្សគាំទ្រដែលបានចុះកិច្ចព្រមព្រៀងរួចហើយជាមួយគណបក្សជាតិ។

លោកKeyបានផ្តល់ឲ្យនូវសេចក្តីសង្ខេបដំបូងអំពីសារដែលលោកបានយកទៅផ្សព្វផ្សាយនៅក្នុងការប្រជុំលើកដំបូងនេះ។

លោកមានប្រសាសន៍ថា"ជាដំបូងយើងមិនត្រូវមើលរំលងពីវិសាលភាពនៃលក្ខណប្រឈមទាំងឡាយឡើយ។ ភាពប្រឈមទាំងនេះគឺជាបញ្ហាសេដ្ឋកិច្ចដ៏លំបាកលំបិន។"

"ហើយជាការពិត២៤ម៉ោងក្រោយពីនេះខ្ញុំនឹងធ្វើដំណើរទៅកាន់ទីក្រុងLimaដែលជាកន្លែងផ្សព្វផ្សាយអន្តរជាតិនូវសារមួយដែលថាបញ្ហាវិបត្តហិរញ្ញវត្ថុនៅតែជាក្តីបារម្ភដ៏ធំធេងសម្រាប់ពិភពលោក"

លោក Key មានប្រសាសន៍ថាថ្ងៃនេះគឺជាថ្ងៃនៃការចាប់ផ្តើមសម្រាប់គម្រោង សកម្មភាព "រយៈពេល១០០ថ្ងៃ" របស់លោក ដែលបានផ្សព្វផ្សាយក្នុងអំឡុងពេល យុទ្ធនាការបោះឆ្នោត។

សភានឹងចាប់ផ្តើមនៅថ្ងៃទី៨ ខែធ្នូ សម្រាប់រយៈពេល២សប្តាហ៍ ហើយច្បាប់ក្នុងការ កាត់បន្ថយពន្ធអាករ ច្បាប់ក្នុងការគ្រប់គ្រងធនធានហើយដំណោះស្រាយទាក់ទិននឹង ច្បាប់និងសណ្តាប់ធ្នាប់នឹងត្រូវបានណែនាំ។

មុនពេលនោះ លោក Key នឹងត្រូវទទួលបាននូវរបាយការណ៍សារពើព័ន្ធចុងក្រោយបំផុត ដែលលោកបានមានប្រសាសន៍ថាមានលក្ខណៈអាក្រក់ជាងតួរលេខដែល ត្រូវបានលាតត្រដាងនៅក្នុងសប្តាហ៍កន្លងទៅ។

រដ្ឋមន្ត្រីនៅក្នុងគណៈរដ្ឋមន្ត្រីដែលបាននិយាយទៅកាន់សារព័ត៌មានមានប្រសាសន៍ថា ពួកគេមានការរំភើបចិត្តដែលបានទទួលតួនាទីនៅទីនោះ។ពួកគេក៏មានសេចក្តី រីករាយផងដែរដែលបានកាន់នូវលិខិតតែងតាំង ដែលចុះហត្ថលេខាដោយអគ្គអភិបាល Anand Satyanand។

ប៉ុន្តែវាក៏មានការយល់ឃើញថារដ្ឋាភិបាលបានចូលទៅកាន់តំណែងនៅក្នុងស្ថានភាពដ៏លំបាកលំបិន ហើយពួកគេត្រូវតែធ្វើការយ៉ាងខ្លាំងដើម្បីស្រោចស្រង់ប្រទេសឲ្យ ផុតពីបញ្ហាអតិផរណាដ៏អាក្រក់នេះ។

សម្រាប់ពួកគេភាគច្រើនវាគឺជាលើកទីមួយហើយដែលពួកគេបានដើរចូលទៅក្នុងបន្ទប់គណៈរដ្ឋមន្ត្រី ដោយមានតុមូលជាច្រើនលំអរដោយកៅអីខ្នងខ្ពស់របស់នាយក រដ្ឋមន្ត្រី។

វាគឺជាលើកទីពីរហើយសម្រាប់លោកKey។ លោកបានសារភាពថា"ខ្ញុំបានផ្តល់ឲ្យនូវ សេចក្តីសង្ខេបដំបូងដ៏កម្រមួយកាលពីម្សិលមិញ"។

## Wong ក្លាយជារដ្ឋមន្ត្រីអាស៊ីដំបូងគេបំផុតរបស់ប្រទេសណូវ៉ែលហ្សេឡង់

Pansy Wong មានប្រសាសន៍ថា ការតែងតាំងលោកស្រីក្នុងតំណែងជារដ្ឋមន្ត្រី គឺជាការបញ្ជូនសារមួយទៅកាន់ពិភព លោកថា ប្រទេសណូវ៉ែលហ្សេឡង់គឺជាប្រទេសមួយ ដែលអ្នកណាក៏អាចត្រូវបានទទួលយក និងទទួលបាននូវភាពជោគ ជ័យ

Pansy Wong មានប្រសាសន៍ថា ការតែងតាំងលោកស្រីជារដ្ឋមន្ត្រីអាស៊ីដំបូង គឺបាន បង្ហាញថា ប្រទេសណូវ៉ែលហ្សេឡង់ គឺជាប្រទេសបើកចំហរ និងមានការអធ្យាស្រ័យ។

សមាជិកសភាដើមកំណើតចិនអាយុ៥៣ឆ្នាំរូបនេះ ត្រូវបានតែងតាំងជារដ្ឋមន្ត្រីទទួលបន្ទុក ការងារជាតិពន្ធ និងជារដ្ឋមន្ត្រីកិច្ចការនារីនៅក្នុងគណរដ្ឋមន្ត្រីថ្មីនៅថ្ងៃនេះ។

លោកស្រី Wong បានឲ្យដឹងថា លោកស្រីតែងតែបានប្រឹងប្រែងទាមទាឲ្យមានការ ប្រតិបត្តិចំពោះលោកស្រីឲ្យដូចជាជនជាតិណូវ៉ែលហ្សេឡង់ដ៏ទៃផ្សេងទៀតដែរ ហើយការ

ជ្រើសរើសលោកស្រីសំរាប់តំបន់ Botany និងការតែងតាំងលោកស្រីជារដ្ឋមន្ត្រី គឺជាការផ្ញើសារមួយជូនពិភពលោកទាំងមូល។

មានប្រសាសន៍ទៅកាន់ NZPA លោកស្រីបានមានប្រសាសន៍ថា ជ័យជំនះនេះបង្ហាញថាប្រទេសណូវែលហ្សេឡង់គឺជាប្រទេសដែលមានការអធ្យាស្រ័យដែលអ្នកណាក៏អាចត្រូវបានគេទទួលយក និងទទួលបាននូវជោគជ័យដែរ។

លោកស្រីសង្ឃឹមថា ជោគជ័យទាំងប៉ុន្មានរបស់លោកស្រី នឹងបង្ហាញទៅដល់ជនជាតិភាគតិចទាំងអស់ថា ពួកគេអាចនឹងទទួលបានជ័យជំនះនៅក្នុងជួគណបក្សធំៗនានា និងនៅក្នុងឆាកនយោបាយ ហើយក៏បានលើកទឹកចិត្តដល់ពួកគេផងដែរឲ្យធ្វើការចូលរួម។

លោកស្រី Wong បានឲ្យតម្លៃប្រព័ន្ធអប់រំការប្រឹងប្រែង និងការតាំងចិត្ត ដែលជាផ្លូវមួយណែនាំដោយម្តាយរបស់លោកស្រីដែលពុំមានការអប់រំ ថាជាកូនសោរសម្រាប់ជ័យជំនះរបស់លោកស្រី។

កើតនៅទីក្រុងសៀងហៃ លោកស្រីព្រមទាំងគ្រួសារបានផ្លាស់ប្តូរទៅរស់នៅទីក្រុងហុងកុងតាំងពីពេលដែលលោកស្រីមានអាយុ៥ឆ្នាំម្ល៉េះ។

ឪពុករបស់លោកស្រីគឺជាអ្នកដើរសមុទ្រដែលទៅឆ្ងាយពីគ្រួសាររយៈពេល៦ខែក្នុងមួយឆ្នាំ ហើយលោកស្រី ម្តាយលោកស្រី និងបងប្អូនប្រុសចំនួនពីរនាក់ទៀតរស់នៅក្នុងបន្ទប់តូចមួយនៃអគាររួមដែលមាន៧គ្រួសារផ្សេងទៀតរស់នៅជាមួយនោះផងដែរ។

"អគារនោះមានមនុស្សប្រហែលជា៥០នាក់។ យើងប្រើប្រាស់ទីធ្លាផ្ទះបាយរួមគ្នា បង្គន់រួមមួយ និងបន្ទប់ទឹករួមមួយ។ ដូច្នេះខ្ញុំធ្លាប់ឆ្លងកាត់ភាពក្រីក្រគោកយ៉ាក។

ទោះបីបរិយាកាសដូច្នេះក៏ដោយ ឪពុកម្តាយរបស់លោកស្រីមានមោទនភាពយ៉ាងខ្លាំងក្នុងការព្យាយាមផ្តល់ឲ្យនូវការអប់រំ និងជីវភាពសមរម្យសម្រាប់កូនៗរបស់ពួកគេ។

"ដោយសារតែបរិដ្ឋានជុំវិញមានលក្ខណៈមិនល្អ លោកស្រីប្រកាន់នូវក្តីស្រមៃមួយថាថ្ងៃណាមួយលោកស្រីនឹងមានផ្ទះផ្ទាល់ខ្លួនមួយដើម្បីរស់នៅ។ ការស្រមៃនេះបានក្លាយជាការពិត៦ឆ្នាំក្រោយមក។

នៅទីក្រុងហុងកុង ការដាក់ឈ្មោះជាភាសាអង់គ្លេសគឺមានការពេញនិយមណាស់។ លោកស្រីដែលមានឈ្មោះពីកំណើត Yu Fong ដែលមានន័យថាក្លិនក្រអូបរបស់ផ្កា បានជ្រើសរើសឈ្មោះជាភាសាអង់គ្លេសថា Pansy។

"ខ្ញុំចូលចិត្តវា។ Pansies មានន័យថាតឹងតែង ប៉ុន្តែវាក៏មានន័យថាសប្បាយ និងមានភាពទាក់ទាញ។ វាទើបតែរហូតមកដល់ពេលក្រោយមក ទើបខ្ញុំដឹងថាឈ្មោះនោះមិនមានក្លិនក្រអូបអ្វីឡើយ។

ក្នុងឆ្នាំ១៩៧៥ នៅពេលដែលលោកស្រីមានអាយុ១៩ឆ្នាំ គ្រួសាររបស់លោកស្រីបានមករស់នៅប្រទេសណូវែលហ្សេឡង់ ក្រោយពីឪពុករបស់លោកស្រីបានមកសំចតកប៉ាល់នៅទីនេះ ហើយយល់ឃើញថា វាជាទីកន្លែងដែលល្អសម្រាប់គ្រួសាររបស់លោក។

លោកស្រី Wong សិក្សានៅសាកលវិទ្យាល័យ Canterbury ហើយក្នុងពេលទំនេរ លោកស្រីជួយធ្វើការលក់ដូរនៅក្នុងហាងគ្រួសារមួយដែលមានឈ្មោះថា St Albans Fish and Chip Shop និង Bealey Ave។

"សូម្បីតែឥឡូវនេះក៏ដោយ ក៏ខ្ញុំនៅតែអាចដុតបិរហ្គ័រធម្មតាមួយបានដែរ"។

ក្នុងពេលសិក្សានៅឯសាកលវិទ្យាល័យ លោកស្រីបានជួបស្វាមីរបស់លោកស្រីគឺលោក Sammy ដែលជាជនជាតិចិនម៉ាឡេស៊ី។

លោកស្រីបានសិក្សាបញ្ចប់សញ្ញាបត្រអនុបណ្ឌិតពាណិជ្ជកម្មលំដាប់កិត្តិយសហើយពេលដំបូងនោះលោកស្រីបានធ្វើការឲ្យ Ernst និង Young ជាគណនេយ្យករ មុនពេល ដែលលោកស្រីបានចូលក្នុងក្រុមហ៊ុន Christchurch Smiths City ដែលជាកន្លែងដែលលោកស្រីបានក្លាយជាប្រធានផ្នែកត្រួតពិនិត្យហិរញ្ញវត្ថុ។

នៅក្នុងឆ្នាំ១៩៨៩ លោកស្រីត្រូវបានគេណែនាំឲ្យចូលប្រឡូកក្នុងឆាកនយោបាយតំបន់ហើយត្រូវបានជ្រើសរើសសំរាប់ Canterbury Regional Council ដែលជាកន្លែងលោកស្រីត្រូវបានគេទទួលស្គាល់ថាជា "ស្ត្រី៦លានដុល្លា"។